គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

TSTD (ADB TA 7305-CAM)

# បច្ចេកទេសចិញ្ចឹមមាន់ស្រុកសម្រាប់ទីផ្សារ


បង្ហាញដោយៈ លោក ស៊ិន ប៉ោ

ជំនាញផ្នែកបសុសត្វ








# ការសាងសង់ទ្រុងកូនមាន់ (អាយុពី ១ ទៅ ៣០ថ្ងៃ)

- ជើងទ្រុងកំពស់ពីដី០,៥ម
- បាតទ្រុង និងជញ្ជាំងធ្វើពីបន្ទះឬស្សី ឬ សំណាញ់ដែក ឬ សំណាញ់នីឡុង។
- បាតទ្រុងក្រាលអង្កាម ឬកំទេចអាចម៍រណា (ដើម្បីរក្សាកំដៅ) រហូតដល់កូនមាន់មានអាយុ ៣០ថ្ងៃ ឬ ១ ខែ
- ជញ្ជាំងទ្រុង និងពីលើទ្រុងពទ្ធ័ដោយបាវ ឬ ក្រដាសដើម្បីរក្សាកំដៅ






# ប្លង់ទ្រុងមេបា និងបំប៉នមាន់សាច់




- បណ្ដោយ ១០ម និង ទទឹង ៥ម
- ចែកខ័ណ្ឌជាបន្ទប់ ដោយសំណាញ់
- មេ ៦ ទៅ ៧ក្បាល ដាក់ បា ១ក្បាល
- ខាងក្នុងមានធ្នើរ សម្រាប់មាន់ដេក
- តសំយ៉ាបចំហៀង សម្រាប់ដាក់ទ្រុងកូន មាន់

# ទ្រុងមេបា និងបំប៉នមាន់សាច់ (ត)



# វដ្តផលិតកម្មកូនមាន់



# ការថែរក្សាកូនមាន់ទើបញាស់



ដាក់មេ និងកូនទើបញាស់ ក្នុងទ្រុងមានក្រាលអង្កាម ឬអាចម៌រណាជាមួយគ្នា រហូតកូនមាន់អាយុ ១០ថ្ងៃ ទើបដកមេមាន់ចេញ



បើត្រជាក់ខ្លាំង ឬពេលយប់ត្រូវបន្ថែមកំដៅ ដោយបាំងជុំវិញទ្រុង ឬប្រើក្អមធ្យូងកំដៅ ឬដាក់អំពូលភ្លើង (មូល)



កូនមាន់អាយុបាន ១ ខែ បញ្ចូលក្នុងទ្រុងបំប៉នមាន់សាច់ ដោយឲ្យដើរសេរីនៅក្នុងទ្រុងបំប៉ន

# ចំណីអាហារសម្រាប់មាន់

ដើម្បីឲ្យមាន់លូតលាស់ល្អត្រូវផ្តល់ចំណីមានសមាសធាតុដូចជា៖

- ជាតិសាច់ (ប្រូតេអ៊ីន)
- ថាមពល
- ជីវជាតិរ៉ែ
- វីតាមីន

# ការផ្តល់ចំណីមេបា និងមាន់ជំទង់

ចំណីបាច
( ផ្សំស្រេច )



៥0%

៥0%





# ការផ្តល់ចំណីកូនមាន់

- ត្រូវផ្តល់ចំណីដែលម៉ត់ ឬល្អិតៗ
- អាយុក្រោម ២១ថ្ងៃ ត្រូវផ្តល់ចំណីផ្សំស្រេចសុទ្ធ (បារ)
- អាយុលើ ២១ថ្ងៃ ត្រូវផ្តល់ចំណីផ្សំស្រេច (បារ) លាយជាមួយកន្ទក់ ចុងអង្ករ និងបន្លែ ១០% ទៅ ២០% (ដើម្បីឲ្យស៊ាំចំណី)

# អនាម័យកន្លែងចិញ្ចឹម

- សំអាតព្រៃជុំវិញកន្លែង (ទ្រុង)ចិញ្ចឹម
- លប់ដីគ្រលុកដក់ទឹកឱ្យបានស្អាតល្អ
- ក្រាលបាតទ្រុងជាមួយអង្កាម ឬ កំទេចអាចម៍រណារ
- បោសសំអាត កើបលាមកចេញរាល់ថ្ងៃ
- សម្លាប់មេរោគ និង បរាសិត (ក្នុង ទ្រុង និងធ្លាចិញ្ចឹម) រៀងរាល់មុនពេលដាក់មាន់ យ៉ាងតិច ១ អាទិត្យ ដោយបាចកំបោរស។





# អនាម័យចំណីអាហារ និងទឹកផឹក

- ផ្តល់ទឹកស្អាតឱ្យមាន់ផឹកៗ ត្រូវផ្លាស់ប្តូរទឹកថ្មីមួយដងក្នុងមួយថ្ងៃ
- ចំណីជុះផ្សិត ផ្អូម មិនត្រូវផ្តល់ឱ្យមាន់ស៊ីទេ

# ការរៀបចំចិញ្ចឹមមាន់

- ត្រៀបចំដាក់តាមប្រភេទ និងជំនាន់ (អាយុ) របស់វា (ក្រុមមេបា ក្រុមកូនជំទង់ និងក្រុមកូនតូចៗ ជាដើម)
- មាន់ទិញ ឬ យកមាន់ចូលថ្មី ត្រូវរក្សាដោយឡែកដាច់ពីគេ ចំនួន ១៤ថ្ងៃ ។ បន្ទាប់មក បើសិនវា មានសុខភាពល្អ ទើបដាក់ចូលជាមួយមាន់ចាស់បាន។





# អនាម័យការឆ្លងពីក្រៅ និងឧបករណ៍ចិញ្ចឹម

- មុនចូលទ្រុងមាន់ ត្រូវសម្លាប់មេរោគ បាតស្បែកជើងដោយជ្រលក់ក្នុងទឹកកំបោរ
- ហាមមិនឱ្យមនុស្សពីក្រៅចូល (អ្នកដើរទិញមាន់ អ្នកចិញ្ចឹមកន្លែងផ្សេង)
- ស្នូកទឹក ស្នូកចំណីត្រូវឧស្សាហ៍លាងសំអាតរៀងរាល់ថ្ងៃ
- បើមាន់ងាប់ដោយជម្ងឺ ត្រូវកប់ ឬ ដុតចោល
- មិនត្រូវបរិភោគមាន់ងាប់ដោយសារជម្ងឺ





# ការប្រើប្រាស់វ៉ាក់សាំងការពារជម្ងឺមាន់

អាយុ ១ ទៅ ៣ ថ្ងៃ



បន្តក់វ៉ាក់សាំង ញ៉ូវកាស
នៅ ភ្នែក ច្រមុះ

អាយុ៧ ទៅ ១០ថ្ងៃ



វ៉ាក់សាំងអុត
ជួសស្លាបវង

អាយុ២ខែ



ចាក់វ៉ាក់សាំង អាសន្នរោគ
នៅសាច់ដុំទ្រូង

អាយុ ២ខែកន្លះ



ទម្លាក់ព្រូន
(លាយចំណី)

# សូមអរគុណ

? ? ?

